*រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ១៩៩៤*

**អនុក្រឹត្យលេខ ៦១ អនក្រ**

**ស្តីពីការផ្តល់ប្រាក់ឧបត្ថម្ភជាបណ្តោះអាសន្ន**

**ដល់មន្ត្រីរាជការ ដែលទទួលភារកិច្ចជួយសង្គ្រោះ**

**អ្នកជំងឺ តាមរថយន្តសង្គ្រោះ**

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

មាត្រា ១ : ផ្តល់ប្រាក់ឧបត្ថម្ភជាបណ្តោះអាសន្នដល់មន្ត្រីរាជការដែលទទួលភារកិច្ចជួយសង្គ្រោះជម្ងឺតាមរថយន្តសង្គ្រោះក្នុងមួយលើកៗដោយកំណត់ដូចខាងក្រោម ៖

-វេជ្ជបណ្ឌិតគ្រូពេទ្យព្យាបាលប្រធានក្រុម ចំនួន៦.០០០រ០០ (ប្រាំមួយពាន់គត់)

-គ្រូពេទ្យមធ្យមជំនួយការប្រធានក្រុមចំនួន ៥.០០០រ០ (ប្រាំពាន់គត់ )

-គិលានុបដ្ឋាក ជួយថែទាំអ្នកជម្ងឺ ចំនួន ៤.០០០រ០០ (បួនពាន់គត់)

-អ្នកបើកបររថយន្ត ចំនួន ៤.០០០រ០០ (បួនពាន់គត់ )

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាលត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

*រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៩៤*

**អនុក្រឹត្យលេខ ១១៥ អនក្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែល ប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-ពិនិត្យសំណូមពរការងារ និង សមត្ថភាពរបស់មន្ត្រីរាជការ

**សំរេច**

មាត្រា ១ : ត្រូវបានតែងតាំងជានាយករងខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី ២ ៖

១- លោក **យី ជន**

២- លោក **ពិត តាំងសាន**

៣- លោក **ប្រាក់ ខណ្ឌឌី**

៤- លោក **ប៊ុន សំបូ**